# ទឹកភ្នែកស្ត្រី

លំនាំបទៈ  ប្រពន្ធដើម

១ ទឹករឿងដើមក្នុងចិត្តចាប់ផ្តើមអួលណែនឈឺផ្សារ   រឿងវិបត្តិអំពើហឹង្សាក្នុងគ្រួសារដ៏សែនវេទនា
កើតពីបុរសគ្មានចិត្តសណ្តោសវាយដំកិរិយា   ធ្វើឱ្យកូនគ្រាំគ្រារស់សែនរងារកណ្តាលលោកីយ៍។

២ ឈប់ភ្លាមទៅអំពើជាន់ឈ្លីគំរាមស្ត្រី   ចាប់រំលោភធ្វើបាបនារីគ្រប់ទិសទីកើតមានរាល់ថ្ងៃ
ខ្លះចាប់កូនឯងខ្លះទៀតចាប់ក្មេងមិនទាន់ពេញវ័យ   កាចសាហាវព្រៃផ្សៃទុកស្រីជាអ្វីសូមជួយប្រាប់ផង?

៣ ឱ!អ្នកម្តាយនឿយទាំងចិត្តកាយគ្មានពេលទំនេរ   ពេលសំរាកមិនហ៊ានឈប់ទេព្រោះហេតុតែគ្រួសារក្រក្រី
កូនសែនអាណិតកូនពិតចង់ជួយអ្នកម្តាយពេកក្រៃ   តែរូបកូនក្មេងខ្ចីហើយនេះជាវ័យកូនស្រីត្រូវរៀន ។

៤ ចូលធ្វើការព្រោះតែពុកម៉ែបានបែកបាក់គ្នា   កូនត្រូវឈប់បន្តវិជ្ជារកការងារសម្រាលបន្ទុក
ចូលរោងចក្រដេរគ្មានពេលទំនេរគ្មានទេថ្ងៃឈប់   គេឱ្យថែមម៉ោងយប់ជួនអីថែមជាប់រហូតដល់ភ្លឺ។

៥ ម៉ោងធ្វើការខុសពីមាត្រាបានកំនត់ឱ្យ   ទោះគេដឹងថាខុសក៏ដោយគេព្រងើយឥតមានគិតគូរ
គេកេងចំណេញកំលាំងពលកម្មពួកយើងរាល់ថ្ងៃ   ព្រោះតែយើងជាស្រីមិនហ៊ានហាស្តីខ្លាចអត់ការធ្វើ។


កម្មវិធីកម្មកររោងចក្រកាត់ដេរ ©២០០៥
និពន្ធនិងច្រៀងដោយកម្មកររោងចក្រកាត់ដេរ